**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
៚ ❖ ៛

**ក្រសួងអប់រំ យុវជន និង កីឡា**
**លេខ :៤០៦ អយក.ប្រក**

# ប្រកាស

## ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ ទួលរកាកុះ មកជាសាលាបឋមសិក្សា ពេញលក្ខណៈ

---

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានពិនិត្យលិខិតលេខ ១២ អយក.ខដ ចុះថ្ងៃទី ១៣ ខែ ០២ ឆ្នាំ ២០០២ របស់ការិយាល័យអប់រំ យុវជន និង កីឡា ខ័ណ្ឌ ដង្កោ រាជធានីភ្នំពេញ ។

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## សំរេច

**ប្រការ១** :-ផ្តាច់សាលាឧបសម្ព័ន្ធ **ទួលរកាកុះ** ចេញពីសាលាបឋមសិក្សា **ព្រៃសរ** ដែលមានទីតាំងស្ថិតនៅភូមិ **ទួលរកាកុះ** សង្កាត់ **ព្រៃសរ** **ខ័ណ្ឌ ដង្កោ រាជធានីភ្នំពេញ** មកជាសាលាបឋមសិក្សាពេញលក្ខណៈវិញ ចាប់ពីឆ្នាំសិក្សា ២០០១ - ២០០២ នេះតទៅ ។

**ប្រការ២** :-សាលាបឋមសិក្សា **ទួលរកាកុះ** ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋាន ប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ៣** :-នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤** :-បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥** :-នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ ការិយាល័យអប់រំ យុវជន និង កីឡា ខ័ណ្ឌ ដង្កោ នាយកសាលាបឋមសិក្សា **ទួលរកាកុះ** នាយកសាលាបឋមសិក្សា **ព្រៃសរ** មានភារកិច្ច អនុវត្តប្រកាសនេះ ។

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សាលាក្រុងភ្នំពេញ

" ដើម្បីជូនជ្រាបជាពត៌មាន "

-ដូចប្រការ ៥- កាលប្បវត្តិ - ឯកសារ នា -ប.ម

ភ្នំពេញ .ថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០០២
ជ-រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ

**អ៊ឹម_សិទ្ធី**